00965396

E295/6/6

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 12 / 2013
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

**ផ្ញើជូន៖** ភាគីទាំងអស់ក្នុងសំណុំរឿង ០០២ — ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៣

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/ លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** **ចម្លើយតបទៅនឹងសំណើរបស់ ក.ស.ច.ស សុំសំណៅដែលមិនបានកោសលុប នៃសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគីក្នុងសំណុំរឿង ០០២/០១**

1. អនុលោមតាមវិធាន ២៩(៤)(ខ) នៃវិធានផ្ទៃក្នុង និងដើម្បីការពារនូវសាក្សីមួយចំនួនដែលជាសាក្សីសក្ដានុពល រួមទាំងដើមបណ្ដឹងរដ្ឋប្បវេណីផងនោះ នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ថា សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគីនៅក្នុងសំណុំរឿង ០០២/០១ ត្រូវស្ថិតនៅជាឯកសារសម្ងាត់ ហើយមានតែសំណៅកោសលុបទេដែលអាចបង្ហាញជាសាធារណៈបាន (ឯកសារ E295/6/5)។

2. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានស្នើសុំឱ្យបង្ហាញសារណាបញ្ចប់ការពិភាក្សាដេញដោល ដើម្បីជួយដល់កិច្ចស៊ើបសួររបស់ខ្លួនដែលកំពុងដំណើរការទៅមុខ ដោយអនុលោមតាមវិធាន ៥៥(៥) មាត្រា ២៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និង មាត្រា ៥ នៃកិច្ចព្រមព្រៀងស្ដីពីបង្កើត អ.វ.ត.ក (ឯកសារ E295/6/6.1)។

3. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សំណើនេះត្រូវបានធ្វើឡើងដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ហេតុដូច្នេះអង្គជំនុំជម្រះយល់ព្រមតាមសំណើនេះ។ អង្គជំនុំជម្រះសាលាដំបូង សូមរម្លឹកដល់ ក.ស.ច.ស ថា សំណៅដើមនៃសារណាបញ្ចប់ការពិភាក្សាដេញដោលដែលមិនបានកោសលុប ត្រូវស្ថិតនៅជាឯកសារសម្ងាត់ដដែល និងឯកសារសំណៅដើមនេះអាចបង្ហាញដល់ភាគីទីបីបាន ប្រសិនបើចាំបាច់តម្រូវឱ្យបង្ហាញឯកសារនេះ នៅក្នុងក្របខណ្ឌរបស់ អ.វ.ត.ក ប៉ុណ្ណោះ។ ក.ស.ច.ស នឹងទទួលបានសារណាបញ្ចប់ការពិភាក្សាដេញដោលមួយច្បាប់ជាទម្រង់អេឡិចត្រូនិក។

4. អនុស្សរណៈនេះ គឺជាចម្លើយតបផ្លូវការទៅនឹងសំណើនោះ។